**ការបើកសាលាជាតំណាក់ៗនៅតែគ្រោងបើកនៅថ្ងៃទី២៩ខែមិនា**

សហគមន៍សាលារៀនក្នុងក្រសួងអប់រំឡុងប៊ីចជាទីមេត្រី,

យើងមានសេចក្ដីរីករាយនឹងផ្ដល់ដំណឹងថាគម្រោងបើកសាលាបង្រៀនផ្ទាល់ជាតំណាក់ៗដែលបានប្រកាសកាលពីសប្ដាហ៍មុននៅតែគ្រោងចាប់ផ្ដើមនៅថ្ងៃទី២៩ខែមិនាដដែល។ ការបង្រៀនផ្ទាល់នៅសាលាបឋមសិក្សាសម្រាប់សាលារៀនសាធារណៈ នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា ត្រូវបានអនុញ្ញាតឱ្យជាទ្រង់ទ្រាយធំជាលើកទីដំបូង ក្នុងរយៈពេលជិតមួយឆ្នាំកន្លងមក យោងទៅតាមលក្ខណៈវិនិច្ឆ័យរបស់រដ្ឋ។ លក្ខណៈវិនិច្ឆ័យទាំងនោះអនុញ្ញាតឱ្យក្រសួងអប់រំឡុងប៊ីចដាក់អនុវត្តនូវគម្រោងរបស់ខ្លួនក្នុងការ បើកសាលាឱ្យសិស្សខ្លះវិលត្រឡប់មករៀននៅសាលាវិញ។ ប្រសិនបើចំនួនករណីកូវិឌបន្តមានភាពប្រសើរឡើង សាលាអនុវិទ្យាល័យនិងវិទ្យាល័យក៏អាចបើកឡើងវិញក្នុងខែមេសា តាមកាលវេលាដែលបានគ្រោងទុក ដូចដែលបានប្រកាសកាលពីសប្ដាហ៍មុន។

កម្រិតអន្តរមត្តេយ្យដល់ទី៥ (TK-5)
ដូចដែលបានប្រកាសកន្លងមក សិស្សដែលត្រឡប់ទៅរៀននៅសាលានៅថ្ងៃទី២៩ខែមិនាគឺសិស្សពីកំរិតថ្នាក់អន្តរមត្តេយ្យ (TK) ដល់ថ្នាក់ទី៥ ដែលមាតាបិតាបានជ្រើសរើសតារាងវេលាសិក្សាប្រភេទហាយប្រ៊ីឌ(ពាក់កណ្ដាលនៅសាលាពាក់កណ្ដាលនៅផ្ទះ)។ មាតាបិតាដែល ចង់ឱ្យកូនគាត់បន្តរៀនទាំងស្រុងតាមអនឡាញ អាចបន្តរៀនតាមជំរើសនោះតទៅទៀត។

ការត្រឡប់ទៅរៀននៅសាលាវិញនៃសិស្សថ្នាក់អន្តរមត្តេយ្យដល់ទី៥ (TK-5) សន្មតថាអត្រាករណីកូវិឌនៅក្នុង ខោនធីឡូសអ៊ិនជើលេសនៅមានកំរិតក្រោម២៥ករណីលើ១០០០០០នាក់ ដូចដែលបានបញ្ជាក់ដោយការណែនាំថ្មីៗរបស់ក្រសួងសុខាភិបាលសាធារណៈជនរដ្ឋកាលីហ្វ័រនីញ៉ា ស្ដីពីការបើកសាលារៀនវិញ។ អត្រាករណីនេះបានធ្លាក់ចុះក្រោមកំរិតចាប់ផ្ដើមនោះកាលពីសប្ដាហ៍មុន។ នៅក្នុងសប្ដាហ៍នេះ អត្រាករណីលើ១០០០០០នាក់គឺ១២.៣ ហើយបានបន្តធ្លាក់ចុះជាច្រើនក្នុងប៉ុន្មានសប្ដាហ៍ថ្មីៗកន្លងមកនេះ។

ក្រសួងអប់រំឡុងប៊ីច LBUSD កំពុងសហការជាមួយក្រសួងសុខាភិបាលក្រុងឡុងប៊ីចដើម្បីចាក់ថ្នាំបង្ការរោគកូវីឌ១៩ដល់បុគ្គលិកសាលាទាំងអស់។ បុគ្គលិក LBUSD រាប់ពាន់នាក់បានទទួល ការចាក់ថ្នាំបង្ការរោគនេះក្នុងប៉ុន្មានសប្ដាហ៍ថ្មីៗកន្លងមកនេះ ដែលផ្ដល់អាទិភាពដល់បុគ្គលិកដែលកិច្ចការរបស់គាត់គឺត្រូវជួបផ្ទាល់នឹងសាធារណៈជន និងគ្រូបង្រៀនក្នុងកំរិតថ្នាក់ទាបៗ។ ទោះបីការចាក់ថ្នាំបង្ការរោគកូវីឌមិនមែនជាការតម្រូវចាំបាច់ដើម្បីអាចវិលត្រឡប់ទៅសាលាវិញ ដោយក្រសួងសុខាភិបាលក្ដី គ្រូបង្រៀនកំរិតថ្នាក់ TK-5 នៅក្នុង LBUSD ដែលនឹងត្រឡប់ទៅបង្រៀននៅសាលាជាធម្មតាវិញនឹងត្រូវផ្ដល់ឱ្យនូវការចាក់ថ្នាំ បង្ការរោគទាំងលើកទីមួយនិងលើកទីពីរ។ គ្រូបង្រៀនទាំងនោះនឹងវិលត្រឡប់ទៅសាលាវិញនៅថ្ងៃទី២២ ខែមិនាដើម្បីរៀបចំថ្នាក់រៀនសម្រាប់សិស្សដែលវិលត្រឡប់មករៀននៅសាលា ស្របពេលដែលការរៀនសូត្រតាមអនឡាញនឹងបន្តធ្វើទៀត។

**កំរិតអនុវិទ្យាល័យនិងវិទ្យាល័យ**

សន្មតថាខោនធីឡូសអ៊ិនជើលេសស្ថិតនៅក្នុងស្ថានភាពតាមលក្ខណៈវិនិច្ឆ័យសុខភាពសាធារណៈជនរបស់រដ្ឋ ការវិលត្រឡប់ទៅរៀននៅសាលាតាមតារាងវេលាហាយប្រ៊ីឌរបស់អនុវិទ្យាល័យនិងវិទ្យាល័យ នឹងចាប់ផ្ដើមកាលវេលាក្រោមនេះ

ដូចដែលបានប្រកាសកាលពីសប្តាហ៍មុនៈ

- ថ្ងៃទី១៩ខែមេសា - ថ្នាក់ទី១២
- ថ្ងៃទី២០ខែមេសា - ថ្នាក់ទី៦ដល់ថ្នាក់ទី៨
- ថ្ងៃទី២៦ខែមេសា - ថ្នាក់ទី៩ដល់ទី១១

គ្រូបង្រៀនសាលាអនុវិទ្យាល័យនិងវិទ្យាល័យនឹងត្រឡប់ទៅសាលារៀនវិញនៅថ្ងៃទី១២ខែមេសាដើម្បីរៀបចំថ្នាក់រៀនសម្រាប់សិស្សដែលវិលត្រឡប់មករៀននៅសាលា ស្របពេលដែលការរៀនសូត្រតាមអនឡាញនឹងបន្តធ្វើទៀត។

លក្ខណៈវិនិច្ឆ័យសុខភាពសាធារណៈរបស់រដ្ឋកាលីហ្វ័រនីញ៉ា មានភាពតឹងរ៉ឹងជាងកំរិតបឋមសិក្សា សម្រាប់ការបើកឡើងវិញនូវកំរិតអនុវិទ្យាល័យនិងវិទ្យាល័យ។ កំរិតអនុវិទ្យាល័យនិងវិទ្យាល័យអាចបើកឱ្យសិស្សត្រឡប់ទៅរៀននៅសាលាវិញបើខោនធីស្ថិតនៅក្នុងកំរិត "ពណ៌ក្រហម" នៃការកំណត់របស់រដ្ឋ ឱ្យបានយ៉ាងតិច៥ថ្ងៃជាប់គ្នា។ ក្នុងកំរិតពណ៌ក្រហមនេះ អត្រាករណីមធ្យមក្នុងកំឡុងរយៈពេល៧ថ្ងៃគឺចន្លោះ៤និង៧លើ១០០០០០នាក់ ហើយចំនួនមនុស្សដែលបានធ្វើតេសមានលទ្ធផលវិជ្ជមានក្នុងកំឡុងរយៈពេល៧ថ្ងៃជាមធ្យមគឺចន្លោះ 5% និង 8% ។ ដូចគ្នានឹងកំរិតសាលាបឋមសិក្សាដែរ ការវិលត្រឡប់ទៅរៀននៅសាលាវិញនេះត្រូវបានផ្តល់ឱ្យប៉ុន្តែមិនមែនជាការតម្រូវចាំបាច់ទេ នៅពេលដែលការបើកសាលានេះត្រូវបានអនុញ្ញាតដោយរដ្ឋ។ សិស្សនឹងមានជំរើស បន្តរៀនតាមអនឡាញ ឬរៀននៅសាលាតាមតារាងវេលាហាយប្រ៊ីឌ។

**កម្មវិធីកីឡានិងសកម្មភាពផ្សេងៗទៀត**

មាតាបិតានឹងទទួលបច្ចុប្បន្នភាពអំពីកម្មវិធីកីឡានិងសកម្មភាពក្រៅម៉ោងសាលាផ្សេងៗ ស្របពេលដែលការណែនាំពីរដ្ឋបន្តវិវត្តទៅមុខ។ រដ្ឋកាលីហ្វ័រនីញ៉ាបានពិនិត្យមើលឡើងវិញលើគោលការណ៍ណែនាំដើម្បីជួយបើកផ្លូវសម្រាប់ឱ្យកីឡាហ្វ៊ុទបិលបាស្កេតបិល សូហ្វបិល បាល់ទាត់ ប៉ូឡូទឹក ការហ៊ោរលើកទឹកចិត្ត(ឈៀលីឌិង) និងកីឡានៅខាងក្រៅដទៃទៀតឱ្យបើកឡើងវិញនៅពេលកម្រិតដែលអាចចាប់ផ្តើមបានត្រូវបានសម្រេច។

**គម្រោងសុខភាពនិងសុវត្ថិភាព**

សុវត្ថិភាពរបស់បុគ្គលិកនិងសិស្សានុសិស្សគឺជាអាទិភាពដំបូងរបស់ក្រសួងអប់រំ។ នៅក្នុងការរៀបចំបំរុងសម្រាប់ឱ្យសិស្សវិលត្រឡប់មកសាលារៀនវិញ ក្រសួងអប់រំឡុងប៊ីចនឹងដាក់ប្រគល់គម្រោងដែលបានកែឡើងវិញមួយទៅដល់ក្រសួងសុខាភិបាលប្រចាំទីក្រុងឡុងប៊ីចនៅថ្ងៃសុក្រនេះដើម្បីឱ្យគេពិនិត្យមើលឡើងវិញ ហើយការឆ្លើយតបត្រូវបានរំពឹងថានឹងបានទទួលមកវិញក្នុងអំឡុងរយៈពេល៧ថ្ងៃ។ គម្រោងបើកសាលានិងគម្រោងសុវត្ថិភាពលើការរាតត្បាតសកលកូវិឌ១៩ របស់ក្រសួងអប់រំឡុងប៊ីចនៅតែមានសម្រាប់សាធារណៈជននៅ lbschools.net/coronavirus ។ គម្រោងនេះកំពុងទទួលការធ្វើបច្ចុប្បន្នភាពដើម្បីផ្តល់ព័ត៌មានថ្មីៗចុងក្រោយគេ ហើយបច្ចុប្បន្នភាពទាំងនោះនឹងត្រូវធ្វើចប់រួចរាល់ក្នុងរយៈពេលខ្លីខាងមុខ។ ក្រសួងអប់រំនៅបន្តបង្ហាញវីដេអូ អំពីសភាពនៃថ្នាក់រៀនជាមួយការដាក់គម្លាតឆ្ងាយពីគ្នា ការសំអាតសម្លាប់មេរោគ និងវិធានការណ៍សុវត្ថិភាពផ្សេងៗទៀត។ សូមទស្សនាឧទាហរណ៍ថ្មីៗនៅត្រង់នេះ ( View the latest example here) .

មាតាបិតានិងអាណាព្យាបាលអាចរំពឹងទទួលព័ត៌មានទាក់ទងនឹងសាលារៀននៅក្នុងរយៈពេលឆាប់ៗទៅថ្ងៃមុខនេះ ស្ដីពី វិធីការសុខភាពនិងសុវត្ថិភាព ដែលមានរួមទាំងការចូលនិងចេញសាលារៀន វិធានការណ៍សម្អាត ការត្បាល់ផ្ទៃកខាងមុខនៃរន្ធច្រមុះធ្វើតែស្ដកូវិឌ (វិធីមួយដែលមានការលុកលុយតិចជាងគេ) និងព័ត៌មានថ្មីៗប្រចាំថ្ងៃផ្សេងទៀត។ ការទំនាក់ទំនងដែលមានមូលដ្ឋាននៅសាលានេះនឹងបណ្ដុះនៅក្នុងគម្រោងសុខភាពនិងសុវត្ថិភាពទូទាំងក្រសួងអប់រំ ដែលផ្ដល់ឱ្យនូវការរំពឹងជាប់លាប់ ខណៈដែលអនុញ្ញាតឱ្យមានការបត់បែននៅសាលារៀនយោងទៅតាមកត្តាផ្សេងៗ ដូចជាចំនួនសិស្សនៅសាលារៀនក្នុងពេលណាមួយជាដើម។

សូមអរគុណដល់ការគាំទ្ររបស់លោកអ្នក ស្របពេលដែលយើងសង្ឃឹមនិងគ្រោងសម្រាប់កភាពប្រសើរឡើង។

ដោយក្ដីស្មោះចំពោះ,

Jill

បណ្ឌិត Jill Baker  អគ្គនាយកសាលារៀន